ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ..០០1.4........អបស/ឱអបស                                                  រាជធានីភ្នំពេញ, ថ្ងៃទី 13 ខែ ០1 ឆ្នាំ២០០៩..

# ប្រកាស

ស្តីពី

## ការកែសម្រួលប្រកាសលេខ ១៥៥អបស/ឱអបស

## ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០០ របស់ក្រសួងសុខាភិបាល

## ស្តីពី បែបបទ និងល័ក្ខខ័ណ្ឌក្នុងការសុំបើក ឬបិទ ឬប្តូរទីតាំង

## នៃគ្រឹះស្ថានលក់ឱសថ

## រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ កញ្ញា ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញ ព្រះរាជក្រម ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ

-បានឃើញ ព្រះរាជក្រម នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី ២៨ ធ្នូ ២០០៧ ប្រកាសឱ្យប្រើច្បាប់ ស្តីពី វិសោធនកម្ម ច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ

-បានឃើញ អនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២២ តុលា ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល

-បានឃើញ ប្រកាសរបស់ក្រសួងសុខាភិបាល លេខ ១៥៥ អបស/ឱអបស ចុះថ្ងៃទី ២១ មីនា ២០០០ ស្តីពី បែបបទ និងល័ក្ខខ័ណ្ឌក្នុងការសុំបើក ឬបិទ ឬប្តូរទីតាំង នៃគ្រឹះស្ថានលក់ឱសថ

-និងយោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល ។

## សំរេច

**ប្រការ១ :** ខ្លឹមសារប្រកាសលេខ ១៥៥ អបស/ឱអបស ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០០ របស់ក្រសួងសុខាភិបាលត្រូវបាន កែសម្រួលដូចខាងក្រោម ។

**ប្រការ២ :** គ្រឹះស្ថានលក់ឱសថចែកចេញជា ៣ប្រភេទ :

-ឱសថស្ថានគ្រប់គ្រងដោយឱសថការី

-ឱសថស្ថានរង "ក" គ្រប់គ្រងដោយឱសថការីមធ្យម

-ឱសថស្ថានរង "ខ" គ្រប់គ្រងដោយមន្ត្រីសុខាភិបាលចូលនិវត្តន៍ដែលមានការិតបច្ចេកទេសជា គិលានុបដ្ឋាក គិលានុបដ្ឋាយិកា និងឆ្មបរដ្ឋ ។



ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល ,លេខ ១៥១-១៥៣ វុក្ខវិថី កម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៨២៦ ០៣៤ / ៨២៦ ៨៤១ ទូរសារ: (៨៥៥-២៣) ៧២២ ៩៣៣

**ប្រការ៣ :** ការបើក ការបិទ ការប្តូរទីតាំង និងការផ្លាស់ប្តូរអ្នកទទួលខុសត្រូវ នៃឱសថស្ថាន និងឱសថស្ថានរង អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ៤ :** ឱសថស្ថាន ឱសថស្ថានរង ដែលបានទទួលការអនុញ្ញាតឱ្យបើកតាមខ្លឹមសារប្រកាសលេខ ១១៥ សនបឱ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩១ និងប្រកាសលេខ ៩៣៧ សនបឱ ចុះថ្ងៃទី ០៦ កញ្ញា ១៩៩៦ និងប្រកាសលេខ ១៥៥ អបស/ឱអបស ចុះថ្ងៃទី ២១ មីនា ឆ្នាំ ២០០០ ត្រូវបានរក្សាសិទ្ធិឱ្យធ្វើពាណិជ្ជកម្មដដែល ។

ក្នុងករណីមានការសុំប្តូរទីតាំង ឬសុំផ្លាស់ប្តូរអ្នកទទួលខុសត្រូវឱសថស្ថាន និងឱសថស្ថានរងខាងលើត្រូវអនុវត្តតាមលក្ខខណ្ឌថ្មី នៃប្រកាសនេះ ។

**ប្រការ៥ :** ចំនួនឱសថស្ថាន ត្រូវកំណត់តាមចំនួនប្រជាពលរដ្ឋក្នុងសង្កាត់ ឃុំជាមូលដ្ឋានតាមសមាមាត្រ ប្រជាពលរដ្ឋយ៉ាងតិច ២០០០នាក់ សំរាប់ឱសថស្ថានមួយកន្លែង ។

ក្រសួងសុខាភិបាល នឹងត្រូវប្រកាសអំពីការបែងចែកចំនួនឱសថស្ថាន តាមសង្កាត់-ឃុំ នីមួយៗក្នុង ១ឆ្នាំ១ដង ។

**ប្រការ៦ :** ទីតាំងឱសថស្ថាន ឱសថស្ថានរង ត្រូវកំណត់តាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

-ឱសថស្ថាន អាចមានទីតាំងនៅគ្រប់ទីកន្លែង ក្នុងព្រះរាជាណាចក្រកម្ពុជា

-ឱសថស្ថានរង "ក" អាចមានទីតាំងនៅក្នុងសង្កាត់-ឃុំ ណា ដែលឱសថស្ថានមានចំនួនមិនទាន់គ្រប់គ្រាន់តាមសមាមាត្រកំណត់ក្នុងប្រការ ៥

-ឱសថស្ថានរង "ខ" អាចមានទីតាំងនៅតាមសង្កាត់-ឃុំណា ដែលឱសថស្ថាន និងឱសថស្ថានរង "ក" មានចំនួនមិនទាន់គ្រប់គ្រាន់តាមសមាមាត្រកំណត់ក្នុងប្រការ ៥ ។

**ប្រការ៧ :** អាចមានសិទ្ធិសុំបើកឱសថស្ថាន ឱសថស្ថានរងបាន ឱសថការី-ឱសថការីមធ្យមទាំងពីរភេទ ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម :

-មានសញ្ជាតិខ្មែរ

-មានសញ្ញាប័ត្រទទួលស្គាល់ពីក្រសួងសុខាភិបាល

-មិនជាប់ក្នុងបញ្ជីថ្កោលទោសពីបទឧក្រិដ្ឋណាមួយ

-មានសុខភាពគ្រប់គ្រាន់អាចបំរើការងារបាន ។

**ប្រការ៨ :** សំណុំលិខិតសុំបើកឱសថស្ថាន ឱសថស្ថានរងមាន :

ក-ពាក្យសុំបើកឱសថស្ថាន ឱសថស្ថានរង មានបិទតែមប្រ៊ី ១.០០០ រៀល "មានគំរូ"

ខ-សញ្ញាប័ត្រឱសថការី ឬឱសថការីមធ្យមទទួលស្គាល់ពីក្រសួងសុខាភិបាល

គ-ជីវប្រវត្តិសង្ខេបរបស់សាម៉ីជន "មានគំរូ"

ឃ-វិញ្ញាបនប័ត្រសុខភាពចេញដោយក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលខេត្ត-ក្រុង

ង-លិខិតថ្កោលទោស ដែលមានរយៈពេលមិនលើសពី បីខែ

ច-គំនូសបំព្រួញទីតាំង ដោយមានចំណារឯកភាពពីមូលដ្ឋានឃុំ/សង្កាត់

ឆ-រូបថតសាម៉ីជន ៤ x ៦ ស.ម ចំនួន ៥ សន្លឹក

សាម៉ីជន ត្រូវបំពេញសំណុំលិខិតខាងលើ ចំនួន ០២ ច្បាប់ ហើយបញ្ជូនមកមន្ទីរសុខាភិបាលខេត្ត-ក្រុង ។

**ប្រការ៩** : ក្នុងករណីចំនួនអ្នកសុំបើកឱសថស្ថាន-ឱសថស្ថានរងច្រើនជាងចំនួនទីតាំងកំណត់ ក្រសួងសុខាភិបាល នឹងផ្តល់អាទិភាព ចំពោះសាម៉ីជនណាដែលបានដាក់ពាក្យសុំបើកមុនគេ និងមានសំណុំលិខិតគ្រប់គ្រាន់ត្រឹមត្រូវតាមការកំណត់ក្នុងប្រការ ៨ ។

**ប្រការ១០** : ក្រសួងសុខាភិបាល នឹងផ្តល់ចម្លើយអំពីការសុំបើក ការប្តូរទីតាំង និងការផ្លាស់ប្តូរអ្នកទទួលខុសត្រូវនៃឱសថស្ថាន-ឱសថស្ថានរង ដល់សាម៉ីជនយ៉ាងយឺតបំផុតក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់តាំងពីថ្ងៃបានទទួលសំណុំលិខិតគ្រប់គ្រាន់ត្រឹមត្រូវ ។

**ប្រការ១១** : ឱសថការី ឬឱសថការីមធ្យម មានសិទ្ធិដាក់ពាក្យសុំបើកឱសថស្ថាន ឬឱសថស្ថានរង បានតែមួយកន្លែង និងមិនអាចប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតឡើយ ។

**ប្រការ១២** : ក្រោយពីបានទទួលសេចក្តីសំរេច ស្តីពី ការបើកឱសថស្ថាន ឬឱសថស្ថានរង ពីក្រសួងសុខាភិបាល សាម៉ីជនត្រូវបើកទ្វារបំរើសាធារណៈជនយ៉ាងយឺតបំផុត ៣ខែ ។ ផុតកំណត់ខាងលើ បើឱសថស្ថាន-ឱសថស្ថានរងគ្មានដំណើរការទេនោះ សេចក្តីសំរេចត្រូវចាត់ទុកជាមោឃៈដោយស្វ័យប្រវត្តិ តាមសេចក្តីសំរេចរបស់មន្ទីរសុខាភិបាលខេត្ត-ក្រុង ។ ក្នុងករណីមានមូលហេតុសមស្រប រយៈកាលកំណត់ខាងលើអាចពន្យាបាន៣ខែទៀត ហើយបានតែមួយដងគត់ តាមសំណើរបស់សាម៉ីជន ។

**ប្រការ១៣** : ក្រសួងសុខាភិបាល មានសិទ្ធិដកហូតវិញនូវសេចក្តីសំរេចស្តីពីការបើក ប្តូរទីតាំង ឬផ្លាស់ប្តូរអ្នកទទួលខុសត្រូវនៃឱសថស្ថាន-ឱសថស្ថានរង ក្នុងករណីពិនិត្យឃើញថា :

ក-អាស័យដ្ឋានទីតាំងផ្ទុយនឹងសេចក្តីសំរេច ស្តីពី ការបើក ឬប្តូរទីតាំង

ខ-សំណុំលិខិតមានលក្ខណៈក្លែងបន្លំ

គ-ឬសាម៉ីជនរៀបចំឱសថស្ថាន-ឱសថស្ថានរង មិនស្របតាមល័ក្ខខ័ណ្ឌកំណត់

ឃ-ឬសាម៉ីជនជាប់ទោសពីបទល្មើសព្រហ្មទណ្ឌ

ង-ឬឱសថស្ថាន-ឱសថស្ថានរង គ្មានដំណើរការក្នុងរយៈពេល ៣ខែ ឬ ៦ខែ តាមការកំណត់ក្នុងប្រការ ១២ ។

**ប្រការ១៤** : ការផ្លាស់ប្តូរទីតាំងឱសថស្ថាន-ឱសថស្ថានរង ពីកន្លែងមួយទៅកន្លែងមួយទៀត អាចអនុញ្ញាតបានលុះត្រាតែការផ្លាស់ប្តូរនោះឋិតក្នុងខ័ណ្ឌ-ស្រុកតែមួយ ពុំមានការផ្លាស់ប្តូរអ្នកទទួលខុសត្រូវទេ និងបានបើកទ្វារបំរើសាធារណជនអស់រយៈពេលលើសពី ៦ខែ មកហើយ ។

**ប្រការ១៥** : សំណុំលិខិតសុំប្តូរទីតាំងមាន :

ក-ពាក្យសុំប្តូរទីតាំង មានបិទតែមប្រ៊ី ១.០០០ រៀល "មានគំរូ"

ខ-សេចក្តីសំរេច ស្តីពី ការបើកឱសថស្ថាន-ឱសថស្ថានរង

គ-គំនូសបំព្រួញទីតាំងថ្មី ដែលមានចំណារឯកភាពពីមូលដ្ឋានឃុំ/សង្កាត់

ឃ-រូបថតសាម៉ីជន ៤ x ៦ ស.ម ចំនួន ៣ សន្លឹក

ឃ-រូបថតសាម៉ីជន ៤ x ៦ ស.ម ចំនួន ៣ សន្លឹក

សាម៉ីជន ត្រូវបំពេញសំណុំលិខិតខាងលើ ចំនួន ០២ ច្បាប់ ហើយបញ្ជូនមកក្រសួងសុខាភិបាល "នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង" តាមរយៈមន្ទីរសុខាភិបាលខេត្ត-ក្រុង ។

**ប្រការ១៦** : ការផ្លាស់ប្តូរអ្នកទទួលខុសត្រូវនៃឱសថស្ថាន ឱសថស្ថានរងពីជនម្នាក់ទៅជនម្នាក់ផ្សេងទៀត អាចអនុញ្ញាតបាន លុះត្រាតែអ្នកទទួលខុសត្រូវថ្មី មានលក្ខណៈសម្បត្តិសមស្របតាមល័ក្ខខ័ណ្ឌកំណត់ក្នុងប្រការ ២ ពុំមានការផ្លាស់ប្តូរទីតាំង បានបើកទ្វារបំរើសាធារណជនអស់រយៈពេលលើសពី ៦ខែ មកហើយ និងមានការឯកភាពជាលាយល័ក្ខអក្សររវាងអ្នកផ្លាស់ចេញ និងអ្នកផ្លាស់ចូល ។

**ប្រការ១៧** : សំណុំលិខិតសុំផ្លាស់ប្តូរអ្នកទទួលខុសត្រូវមាន :

ក-ពាក្យសុំមានបិទតែមប្រ៊ី ១.000 រៀល

ខ-កិច្ចព្រមព្រៀងរវាងអ្នកផ្លាស់ចេញ និងអ្នកផ្លាស់ចូល

គ-សេចក្តីសំរេចស្តីពីការបើកឱសថស្ថាន ឱសថស្ថានរង

ឃ-សញ្ញាប័ត្រឱសថការី ឬឱសថការីមធ្យមទទួលស្គាល់ពីក្រសួងសុខាភិបាលរបស់អ្នកផ្លាស់ចូល

ង-ជីវប្រវត្តិសង្ខេបរបស់អ្នកផ្លាស់ចូល

ច-វិញ្ញាបនប័ត្រសុខភាពរបស់អ្នកផ្លាស់ចូលចេញដោយក្រសួងសុខាភិបាលឬមន្ទីរសុខាភិបាលខេត្ត-ក្រុង

ឆ-លិខិតថ្កោលទោស ដែលមានរយៈពេលមិនលើសពី បីខែ របស់អ្នកផ្លាស់ចូល

ជ-រូបថតសាម៉ីជនអ្នកផ្លាស់ចូល ៤ x ៦ ស.ម ចំនួន ៥ សន្លឹក ។

សាម៉ីជន ត្រូវបំពេញសំណុំលិខិតខាងលើ ចំនួន ០២ ច្បាប់ ហើយបញ្ជូនមកក្រសួងសុខាភិបាល "នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង" តាមរយៈមន្ទីរសុខាភិបាលខេត្ត-ក្រុង ។

**ប្រការ១៨** : ឱសថស្ថានរងប្រភេទ "ក" ដែលគ្រប់គ្រងដោយឱសថការីមធ្យមអាចដាក់ពាក្យសុំប្តូរប្រភេទជាឱសថស្ថានវិញបានប្រសិនបើ ឱសថការីមធ្យមនោះបានក្លាយខ្លួនជាឱសថការីឧត្តម ដោយពុំមានការផ្លាស់ប្តូរទីតាំង ឬអ្នកទទួលខុសត្រូវទេ និងបានបើកទ្វារបំរើសាធារណជនអស់រយៈពេលលើសពី ៦ខែ មកហើយ ។

**ប្រការ១៩** : សំណុំលិខិតសុំប្តូរប្រភេទឱសថស្ថានមាន :

ក-ពាក្យសុំប្តូរឱសថស្ថានមានបិទតែមប្រ៊ី ១.000 រៀល

ខ-សេចក្តីសំរេចស្តីពីការបើកឱសថស្ថានរង "ច្បាប់ដើម"

គ-សញ្ញាប័ត្រឱសថការី ទទួលស្គាល់ពីក្រសួងសុខាភិបាល

សាម៉ីជន ត្រូវបំពេញសំណុំលិខិតខាងលើ ចំនួន ០២ ច្បាប់ ហើយបញ្ជូនមកក្រសួងសុខាភិបាល "នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង" តាមរយៈមន្ទីរសុខាភិបាលខេត្ត-ក្រុង ។

**ប្រការ២០** : ការរៀបចំឱសថស្ថាន-ឱសថស្ថានរង :

ឱសថស្ថាន ឱសថស្ថានរង ត្រូវចែកចេញពីការស្នាក់នៅ មានអនាម័យស្អាតបាតទាំងខាងក្នុង ទាំងខាងក្រៅ និងមានការរៀបចំសមស្របតាមការកំណត់ដូចខាងក្រោម :

ក-មានផ្ទៃក្រឡាអាជីវកម្មយ៉ាងតិច ២០ម² សំរាប់ឱសថស្ថាន និង ១៦ម² សំរាប់ឱសថស្ថានរង

ខ-មានស្លាកសញ្ញាឱសថស្ថាន-ឱសថស្ថានរង ដែលមានផ្ទៃពណ៌ស អក្សរពណ៌ទឹកប៊ិច ទំហំយ៉ាងតូច ០.៦ x ៣.៨ម៉ែត្រ

គ-ហាមផ្សព្វផ្សាយពាណិជ្ជកម្មតាមគ្រប់រូបភាព លើស្លាកសញ្ញាឱសថស្ថាន-ឱសថស្ថានរង

ឃ-មានទូរកញ្ចក់ស្អាតបាតពណ៌សគ្រប់គ្រាន់សំរាប់តាំងឱសថ បរិក្ខារពេទ្យ ...

ង-មានទូរបញ្ជរសំរាប់បេឡាការី និងអ្នកប្រគល់ឱសថ

ច-មានទូរថ្នាំពិសេសសំរាប់ស្តុកគ្រឿងញៀន និងថ្នាំប្រព័ន្ធសរសៃប្រសាទ

ឆ-មានទូរទឹកកកសំរាប់ស្តុកឱសថ ដែលទាមទារការទុកដាក់ក្នុងសីតុណ្ហភាពកំណត់

ជ-មានជញ្ជីងសំរាប់ថ្លឹងទម្ងន់

ឈ-ឃ្លាំងស្តុកឱសថប្រសិនបើមាន ត្រូវមានលក្ខណៈសមស្របតាមបច្ចេកទេសឱសថសាស្ត្រ

ញ-បន្ទប់ផ្សំឱសថប្រសិនបើមាន ត្រូវរៀបចំឱ្យបានសមស្របតាមបច្ចេកទេសឱសថសាស្ត្រ

ដ-មានតុសំរាប់ឱសថការីធ្វើការ ។

**ប្រការ២១ :** ឱសថស្ថាន ឱសថស្ថានរង អាចតាំងលក់នូវប្រភេទទំនិញដូចខាងក្រោម :

ក-ឱសថសំរាប់វិស័យសុខាភិបាល

ខ-ផលិតផលអនាម័យខ្លួនប្រាណមនុស្ស គ្រឿងសំអាង ផលិតផលឌីយេតេទិក ដែលមានគុណភាពបង្ការ ឬព្យាបាលជម្ងឺ

គ-សម្ភារៈបរិក្ខារពេទ្យ និងទន្តពេទ្យ

ឃ-សម្ភារៈ ប្រតិករ សំរាប់មន្ទីរពិសោធន៍ វេជ្ជសាស្ត្រ-ឱសថសាស្ត្រ ។

**ប្រការ២២ :** ឱសថស្ថាន មានសិទ្ធិដូចតទៅ :

ក-លក់ដុំ និងលក់រាយ នូវផលិតផលដូចមានចែងក្នុងប្រការ ២១ ជូនដល់អង្គភាពសេវាសុខាភិបាលរដ្ឋ ឯកជន ឱសថស្ថានរង និងអតិថិជនសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន

ខ-ផ្សំឱសថមួយចំនួនតាមវេជ្ជបញ្ជា ឬតាមក្បួនឱសថសាស្ត្រ

គ-បញ្ជាទិញផលិតផលឱសថ តែពីគ្រឹះស្ថានផលិតឱសថ ឬគ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថ ។

**ប្រការ២៣ :** ឱសថស្ថានរងមានសិទ្ធិដូចតទៅ :

ក-លក់រាយ នូវផលិតផលដូចមានចែងក្នុងប្រការ ២១ តាមបញ្ជីកំណត់របស់ក្រសួងសុខាភិបាល ជូនដល់អតិថិជនសំរាប់ការប្រើប្រាស់ក្នុងការព្យាបាលជម្ងឺផ្ទាល់ខ្លួន ។

ខ-បញ្ជាទិញផលិតផលឱសថតែពីឱសថស្ថាន ។

**ប្រការ២៤ :** បែបបទពាណិជ្ជកម្ម

ក-ក្នុងឱសថស្ថាន ឱសថស្ថានរង ត្រូវមានវត្តមានរបស់អ្នកទទួលខុសត្រូវ ( ឱសថការី ឱសថការីមធ្យម ឬមន្ត្រីសុខាភិបាលចូលនិវត្តន៍) ដើម្បីគ្រប់គ្រងសកម្មភាពក្នុងគ្រឹះស្ថានលក់ឱសថរបស់ខ្លួន ។

ខ-អ្នកលក់ត្រូវពាក់អាវពេទ្យពណ៌ស (Blouse) និងមានពាក់ស្លាកឈ្មោះ ។

គ-អ្នកលក់ត្រូវចេះអាន សរសេរ ចេះបកស្រាយវេជ្ជបញ្ជា និងបរិយាយបណ្ណឱសថ ។

ឃ-ត្រូវចុះឈ្មោះឱសថ (ថ្នាំញៀន និងថ្នាំប្រព័ន្ធសរសៃប្រសាទ) ដែលបានផ្តល់ជូនអតិថិជនក្នុង សៀវភៅស្រង់វេជ្ជបញ្ជា ។

ង-នៅពេលផ្តល់ឱសថតាមវេជ្ជបញ្ជា ត្រូវពិនិត្យឱ្យបានច្បាស់អំពីឈ្មោះ និងហត្ថលេខារបស់គ្រូពេទ្យព្យាបាល ឈ្មោះឱសថ ចំនួន កំរិតនិងរបៀបប្រើ ។ ប្រសិនបើពិនិត្យឃើញវេជ្ជបញ្ជាមានលក្ខណៈមិនត្រឹមត្រូវ ឬប្រើលើសកំរិត ឬប្រើខុសក្បួនវេជ្ជសាស្ត្រ ត្រូវឱ្យអតិថិជនទៅសុំការបញ្ជាក់សារជាថ្មីពីគ្រូពេទ្យព្យាបាល និងមិនត្រូវលក់ទាំងប្រថុយប្រថានឡើយ ។

ច-នៅលើវេជ្ជបញ្ជាដែលបានផ្តល់ឱសថរួចហើយ ត្រូវបោះត្រាឱសថស្ថាន ឬឱសថស្ថានរង និងមានចុះកាលបរិច្ឆេទលក់ឱសថ ពិសេសថ្នាំញៀន និងថ្នាំប្រព័ន្ធសរសៃប្រសាទ ។

ប្រការ២៥ : ត្រូវហាមឃាត់ :

ក-ការតាំងលក់ឱសថដែលមានប្រភពមិនស្របច្បាប់

ខ-ការតាំងលក់ឱសថដែលគ្មានលតប័ត្រ (Vignette)

គ-ការតាំងលក់ឱសថដែលក្រសួងសុខាភិបាលបានហាមឃាត់

ឃ-ការតាំងលក់ឱសថផុតកំណត់ពេលប្រើប្រាស់

ង-ការតាំងលក់ផលិតផលដែលមិនបានកំណត់ក្នុងប្រការ ២១

ច-ការប្រកបអាជីវកម្មផ្សេងទៀត ក្នុងគ្រឹះស្ថានលក់ឱសថ ។

ប្រការ២៦ : ក្នុងករណីអវត្តមានរបស់អ្នកទទួលខុសត្រូវ (ឱសថការី ឬឱសថការីមធ្យម ឬមន្ត្រីសុខាភិបាលចូលនិវត្តន៍) ដែលមានរយៈពេលគិតចាប់ពី ១ឆ្នាំ ឱសថស្ថាន-ឱសថស្ថានរងនោះ ត្រូវមានអ្នកទទួលខុសត្រូវជំនួសដែលមានលក្ខណៈសម្បត្តិជា :

-ឱសថការីឧត្តម ឬនិស្សិតឱសថសាស្ត្រឆ្នាំទី៥ ចំពោះឱសថស្ថាន

-ឱសថការីមធ្យម ចំពោះឱសថស្ថានរង "ក"

-មន្ត្រីសុខាភិបាលចូលនិវត្តន៍ ដែលមានកំរិតបច្ចេកទេសសមស្រប ចំពោះឱសថស្ថានរង "ខ"

ការជំនួសខាងលើ អាចចូលជាធរមានបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ២៧ : រយៈកាលនៃការជំនួសមិនអាចលើសពី ១ឆ្នាំបានទេ លើកលែងតែក្នុងករណីមានមូលហេតុសមស្រប ឬមរណភាពរបស់អ្នកទទួលខុសត្រូវទើបរយៈកាលនៃការជំនួសអាចពន្យាបានមួយឆ្នាំទៀត ។ ចំពោះឱសថស្ថានរង "ខ" បើអ្នកទទួលខុសត្រូវទទួលមរណភាព ការធ្វើអាជីវកម្មត្រូវអស់សុពលភាព ។

ប្រការ២៨ : ខ្លឹមសារប្រកាសលេខ ១៥៩ អបស/ឱអបស ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០០ របស់ក្រសួងសុខាភិបាល ព្រមទាំងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ២៩ :** អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងមន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ៣០ :** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ម៉ម_ប៊ុនហេង

ចំលងជូន :

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី

ក្រសួងយុត្តិធម៌

- ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច
- សាលាក្រុងភ្នំពេញ និងខេត្ត-ក្រុង

"ដើម្បីជ្រាបជាព័ត៌មាននិងសហការ"

- ក្រសួងព័ត៌មាន "ដើម្បីជួយផ្សព្វផ្សាយ"
- អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- លេខាធិការដ្ឋានគណកម្មាធិការនិងគណកម្មការខេត្ត-ក្រុង

លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់

- នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង
- មន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងខេត្ត-ក្រុង២៤
- គ្រឹះស្ថានលក់ឱសថដែលពាក់ព័ន្ធ

"ដើម្បីអនុវត្តន៍"

- ឯកសារ
- កាលប្បវត្តិ